ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# មគ្គុទ្ទេសក៍សំរាប់ការបង្ការ និង ថែទាំព្យាបាលជំងឺតាឡាសេមី នៅប្រទេសកម្ពុជា

សំរាប់មន្ទីរពេទ្យបង្អែកនៅប្រទេសកម្ពុជា

នាយកដ្ឋានការពារសុខភាព

កម្មវិធីបង្ការ និង ទប់ស្កាត់ជំងឺមិនឆ្លង

ភ្នំពេញ ខែកញ្ញា ឆ្នាំ២០១១

សហព័ន្ធតាឡាសេមីអន្តរជាតិបានផ្តួចផ្តើម និង គាំទ្រនាយកដ្ឋានការពារសុខភាពនៃក្រសួងសុខាភិបាល ក្នុងការរៀបចំសិក្ខាសាលាដើម្បីពិនិត្យសំរេចសៀវភៅមគ្គុទេសក៍សម្រាប់ការបង្ការ និង ថែទាំព្យាបាលជំងឺតាឡាសេមីនៅប្រទេសកម្ពុជា។ ខ្លឹមសារនៃសៀវភៅនេះ ត្រូវបាន ព្រៀង និង កែសំរេចឡើង ដោយក្រុមគ្រូពេទ្យនៃព្រះរាជាណាចក្រកម្ពុជា។

បោះពុម្ពលើកទីមួយដោយ
សហព័ន្ធតាឡាសេមីអន្តរជាតិ
ចំនួន ៤០០ ក្បាល

# អារម្ភកថា

សៀវភៅមគ្គុទេសក៍សម្រាប់ការបង្ការនិងថែទាំព្យាបាលជំងឺតាឡាសសេមីនៅប្រទេសកម្ពុជានេះរៀបរៀងឡើងតាមសំណូមពររបស់គ្រូពេទ្យព្យាបាលនៅតាមមន្ទីរពេទ្យបង្អែកក្នុងព្រះរាជាណាចក្រកម្ពុជា។ គោលបំណងចម្បងរបស់សៀវភៅនេះ គឺផ្តល់គោលការណ៍ណែនាំសំខាន់ៗដល់គ្រូពេទ្យព្យាបាលក្នុងការធ្វើរោគវិនិច្ឆ័យជំងឺតាឡាសសេមី និង ជំងឺហេមូក្លូបីនមួយចំនួនផ្សេងទៀត ព្រមទាំងជាជំនួយស្មារតី សម្រាប់ការគ្រប់គ្រងព្យាបាលកន្សោមរោគសញ្ញាដ៏ស្មុគស្មាញទាំងនេះ រួមទាំងបញ្ហាសុខភាពពាក់ព័ន្ធមួយចំនួនដែលអ្នកជំងឺតាឡាសសេមីកំពុងនឹងប្រឈមមុខ។ ម្យ៉ាងវិញទៀតសៀវភៅមគ្គុទេសក៍នេះ ជំនួយក្នុងការលើកកម្ពស់ចំណេះដឹងរបស់ប្រជាពលរដ្ឋស្តីអំពីយុទ្ធសាស្ត្របង្ការជំងឺនេះ ដោយផ្តោតលើការស្រាវជ្រាវរកអ្នកដែលផ្ទុកនូវ(β)តាឡាសសេមី និង ជំងឺហេមូក្លូបីនមួយចំនួនផ្សេងៗទៀត ដូចជាការផ្តល់ប្រឹក្សាមុនកំណើតដល់បុគ្គលដែលមានបញ្ហា ក៏ដូចជាការពន្យល់ប្រាប់ឱ្យដឹងជាមុន ដល់គូរស្រករដែលមានបញ្ហានេះ អំពីលទ្ធភាពនៃការផ្តល់កំណើតដល់ទារកដែលមានជំងឺដូចឪពុកម្តាយដែរ។

ខ្លឹមសាររបស់សៀវភៅមគ្គុទេសក៍នេះ ត្រូវបានរៀបរៀងឡើងដោយផ្អែកទៅលើមគ្គុទេសក៍របស់សហព័ន្ធអន្តរជាតិនៃជំងឺតាឡាសសេមី និង ជាពិសេសផ្អែកទៅលើមតិឯកភាពនៃអង្គប្រជុំរបស់គ្រូពេទ្យព្យាបាលថ្នាក់ខេត្ត និង ថ្នាក់កណ្តាល ជាមួយនឹងក្រុមការងារបង្ការ និង ទប់ស្កាត់ជំងឺតាឡាសសេមីរបស់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។ សៀវភៅនេះ ជាជំនួយដល់គ្រូពេទ្យព្យាបាល មិនមែនជាសៀវភៅវេជ្ជសាស្ត្រដែលគ្របដណ្តប់គ្រប់បញ្ហាដែលអ្នកព្យាបាលតែងតែប្រឈមមុខជាមួយនៅពេលព្យាបាលជំងឺនៅតាមមន្ទីរពេទ្យសាធារណៈនោះទេ។

ខ្ញុំមានជំនឿមុតមាំថា សៀវភៅនេះនឹងផ្តល់នូវអត្ថប្រយោជន៍ដល់គ្រប់គ្រូពេទ្យព្យាបាលទាំងអស់ក្នុងការផ្តល់សេវាព្យាបាលមួយដែលមានគុណភាព និង ប្រសិទ្ធិភាពជូនដល់ប្រជាពលរដ្ឋ។

ភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១១

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

សាស្ត្រាចារ្យ អេង_ហួត

## ចូលរួមពិនិត្យ និង កែសំរួលដោយ

| | |
|---|---|
| វេជ្ជ. គីម អាង | គ្រូពេទ្យឯកទេសជំងឺកុមារ ប្រធានផ្នែកអគារ **ក** មន្ទីរពេទ្យកុមារជាតិ |
| វេជ្ជ. អ៊ាប គឹកឆេង | គ្រូពេទ្យឯកទេសជំងឺកុមារ ប្រធានផ្នែកអគារ **ខ** មន្ទីរពេទ្យកុមារជាតិ |
| វេជ្ជ. ឌឿង ថា | មន្ទីរពេទ្យកុមារជាតិ |
| វេជ្ជ. តាំង វឌ្ឍមុនី | មន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត |
| វេជ្ជ. ឈីវ យឹម | មន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត |
| វេជ្ជ. អ៊ី សុភារិទ្ធ | មន្ទីរពេទ្យមិត្តភាពកម្ពុជាសូវៀត |
| វេជ្ជ. ហុក ស៊ីវ៉ានី | អនុប្រធានការិ.ប្រយុទ្ធនឹងជំងឺមិនឆ្លង នាយកដ្ឋានការពារសុខភាព |
| វេជ្ជ. សាន សៀនដារ៉ុង | ការិ.ប្រយុទ្ធនឹងជំងឺមិនឆ្លង នាយកដ្ឋានការពារសុខភាព |
| វេជ្ជ. យិត ស៊ុនណារ៉ាក់ | នាយកដ្ឋានមន្ទីរពេទ្យ |
| វេជ្ជ. យិល ដារ៉ាវុធ | អង្គការសុខភាពពិភពលោក |
| វេជ្ជ. លន ទ្រីយ៍ប៉ាទ្រិច | គ្រូពេទ្យឯកទេសជំងឺកុមារ មន្ទីរពេទ្យខេត្តកំពង់ចាម |
| វេជ្ជ. ម៉ី មុនីបូរិន្ទ | គ្រូពេទ្យឯកទេសជំងឺកុមារ មន្ទីរពេទ្យខេត្តកំពង់ចាម |
| វេជ្ជ. តែ វ៉ាន់ថា | គ្រូពេទ្យឯកទេសជំងឺកុមារ មន្ទីរពេទ្យខេត្តតាកែវ |
| វេជ្ជ. សុខ គង់ | មន្ទីរពេទ្យខេត្តកំពង់ឆ្នាំង |
| វេជ្ជ. ណា វ៉ាន់នី | មន្ទីរពេទ្យខេត្តពោធិសាត់ |

## ក្រុមការងាររៀបចំយុទ្ធសាស្ត្របង្ការនិងទប់ស្កាត់ជំងឺតាឡាសសេមី

| | |
|---|---|
| ឯ.ឧ.សា. យិត ស៊ុនណារ៉ា | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល |
| វេជ្ជ. ប្រាក់ ពិសិដ្ឋរង្សី | ប្រធាននាយកដ្ឋានការពារសុខភាព |
| វេជ្ជ. ថាច វ៉ារិន | អនុប្រធាននាយកដ្ឋានការពារសុខភាព |
| វេជ្ជ. ហុក គឹមចេង | អនុប្រធានមជ្ឈមណ្ឌលជាតិផ្តល់ឈាម |
| ឱ. ខង្ស យុគលី | ប្រធានការិ.បច្ចេកទេស មជ្ឈមណ្ឌលជាតិផ្តល់ឈាម |
| វេជ្ជ. ថាន សុផល | គ្រូពេទ្យឯកទេសជំងឺកុមារ គ្លីនិកលោហិតសាស្ត្រកុមារ អាគារក មន្ទីរពេទ្យកុមារជាតិ |
| វេជ្ជ. សោម រិទ្ធី | មជ្ឈមណ្ឌលគាំពារមាតា និង ទារក |
| វេជ្ជ. ប៊ុនចាន់ យុត្តិរុង | គ្រូពេទ្យឯកទេសជំងឺកុមារ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល |
| ឱ. គ្រៀល សុផល | វិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| លោក គីម ហួត | វិទ្យាស្ថានជាតិសុខភាពសាធារណៈ |
| វេជ្ជ. ឈុន លន់ | ប្រធានការិ.ប្រយុទ្ធនឹងជំងឺមិនឆ្លង នាយកដ្ឋានការពារសុខភាព |
| វេជ្ជ. សុខ គង់ | អនុប្រធានការិ.ប្រយុទ្ធនឹងជំងឺមិនឆ្លង នាយកដ្ឋានការពារសុខភាព |
| វេជ្ជ. យឹម សំអាត | អង្គការសុខភាពពិភពលោក |
| អ្នកស្រី Robyn Devenish | អ្នកឯកទេសមន្ទីរពិសោធន៍វេជ្ជសាស្ត្រ |
| វេជ្ជ. Nicole Seguy | អង្គការសុខភាពពិភពលោក |
| វេជ្ជ. Suzan Jack | អង្គការសុខភាពពិភពលោក |
| វេជ្ជ. ស៊ឹង ហេង | គ្រូពេទ្យឯកទេសជំងឺកុមារ ប្រធានផ្នែកជំងឺសំរាកពេទ្យ មន្ទីរពេទ្យកុមារអង្គរ |
| លោក អៀង អូនតូច | ប្រធានសមាគមតាឡាសេមីកម្ពុជា |
| វេជ្ជ. Joby George | អង្គការទស្សនៈពិភពលោកអន្តរជាតិ |
| វេជ្ជ. Joel Conkle | អង្គការយូនីសេហ្វ |

# សេចក្តីថ្លែងអំណរគុណ

ជាបឋមសូមថ្លែងអំណរគុណ យ៉ាងជ្រាលជ្រៅ ជូនចំពោះសហព័ន្ធជំងឺតាឡាសសេមីអន្តរជាតិ (TIF) ដែលបានជួយឧបត្ថម្ភទាំងផ្នែកបច្ចេកទេស និង ទាំងផ្នែកថវិកា ដល់ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីរៀបរៀងសៀវភៅមគ្គុទេសស៍សំរាប់ការបង្ការ និង ថែទាំព្យាបាលជំងឺតាឡាសសេមីនៅកម្ពុជា។

សូមថ្លែងអំណរគុណចំពោះលោកវេជ្ជបណ្ឌិត **Michael Angastiniotis**

Consultant of Pediatrics
Ex-Director of the WHO Collaborating Centre for Thalassaemia, Ministry of Health, Nicosia, Cyprus
TIF Medical Advisor, Cyprus
WHO Expert Advisory Panel on Human Genetics
ដែលបានជួយពិនិត្យកែសំរួលសៀវភៅមគ្គុទេសក៏នេះ។

សូមថ្លែងអំណរគុណចំពោះលោកវេជ្ជបណ្ឌិត **ជាន សុផល**

គ្រូពេទ្យកុមារ និង លោហិតសាស្ត្រ
គ្លីនិកលោហិតសាស្ត្រកុមារ / អាគារ ក, មន្ទីរពេទ្យកុមារជាតិ, ភ្នំពេញ
ទីប្រឹក្សាវេជ្ជសាស្ត្រ, សមាគមតាឡាសសេមីកម្ពុជា
ដែលបានខិតខំ និង លះបង់ពេលវេលាដ៏មានតម្លៃ ជួយរៀបរៀងខ្លឹមសារដំបូងរបស់សៀវភៅមគ្គុទេសក៏នេះ

សូមថ្លែងអំណរគុណចំពោះការផ្តល់វិភាគទានពី **លោកស្រី រ៉ូប៊ីន ឌីវីនីស**

អ្នកវិទ្យាសាស្ត្រមន្ទីរពិសោធន៍វេជ្ជសាស្ត្រ,
ទីប្រឹក្សាមន្ទីរពិសោធន៍វេជ្ជសាស្ត្រនៃមន្ទីរពេទ្យកុមារជាតិ
ដែលបានជួយពិនិត្យផ្នែកមន្ទីរពិសោធន៍នៃកូនសៀវភៅនេះ ហើយបានផ្តល់នូវការណែនាំជំនាញព្រមទាំងអនុសាសន៍ដ៏មានតំលៃ ។

សូមថ្លែងអំណរអរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះគ្រូពេទ្យជំនាញនានា ក៏ដូចជាគ្រូពេទ្យព្យាបាលទាំងថ្នាក់ជាតិ និង ទាំងថ្នាក់ខេត្ត រួមទាំងក្រុមការងាររៀបចំយុទ្ធសាស្ត្របង្ការ និង ទប់ស្កាត់ជំងឺតាឡាសសេមីក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលបានចូលរួមប្រជុំពិនិត្យសំរេចសៀវភៅនេះ។

# មាតិការឿង

អារម្ភកថា

សេចក្តីផ្តើម

តើអ្វីជាជំងឺតាឡាសេមី ?

ភាពខ្វិនថយខាងបរិមាណក្នុងការធ្វើសំយោគអេម៉ូក្លូប៊ីន - ជំងឺតាឡាសេមី

ភាពខ្វិនថយខាងគុណភាពក្នុងការធ្វើសំយោគអេម៉ូក្លូប៊ីន - ជំងឺអេម៉ូក្លូប៊ីន

ការវិភាគរករោគ និង ការការពារ (Screening and Prevention)

ក្រុមឧបត្ថម្ភគាំទ្រ

ជំហានក្នុងការពិនិត្យកុមារស្លេកស្លាំង

បំរែបំរួលនៃ CBC indices តាមអាយុ

ការវិភាគស្រាវជ្រាវជាមូលដ្ឋានដែលត្រូវធ្វើចំពោះអ្នកជំងឺថ្មី

ការថែទាំព្យាបាល

ការបញ្ចូលឈាម

Beta - Thalassemia major

Beta - Thalassemia intermedia

Alpha - Thalassemia (Hb H disease)

ការព្យាបាលកំចាត់ជាតិដែក

ថ្នាំកំចាត់ជាតិដែកចាក់ក្រោមស្បែក ឬ ចាក់តាមសរសៃឈាម

ថ្នាំកំចាត់ជាតិដែកលេបតាមមាត់

ការព្យាបាលដោយផ្គុំថ្នាំកំចាត់ជាតិដែក

ការតាមដានពិនិត្យអ្នកជំងឺ

ការវះកាត់អណ្តើកចេញ

របបអាហារ និង សារធាតុបន្ថែម

ការចាក់ថ្នាំបង្ការ

ការបង្ករោគរាតត្បាតស្រួចស្រាវ

ឯកសារពិគ្រោះ

# សេចក្តីផ្តើម / Introduction

Thalassemia major ជាជំងឺឈាមតំណពូជដែលស្តែងចេញជាភាពស្លេកស្លាំង (anemia) ភាគច្រើនតាំងពីអាយុ ៤ - ៦ ខែម្ល៉េះ ដោយបង្ហាញជារោគសញ្ញារហិតរហៃ (lethargy), មិនលូតលាស់ធំធាត់ និង ការរីកធំនៃថ្លើម-អណ្តើក (hepatosplenomegaly) ។

ការពង្រីកសេវាថែទាំសុខភាពបឋម ត្រូវរួមបញ្ចូលការងារអភិបាលទៀងទាត់លើការបញ្ចូលឈាម និង ការផ្តល់ឱសថចាំបាច់តាមការថែទាំព្យាបាលជាស្តង់ដា ដែលជាតំរូវការចាំបាច់នាពេលបច្ចុប្បន្ននេះសំរាប់អ្នកជំងឺក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។

ហេតុដូច្នេះហើយទើប **សៀវភៅមគ្គុទ្ទេសក៍សំរាប់ការបង្ការ និង ថែទាំព្យាបាលជំងឺតាឡាសសេមីនៅប្រទេសកម្ពុជា**ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់គុណភាពការផ្តល់សេវាថែទាំអ្នកជំងឺតាឡាសសេមីឱ្យបានសមស្រប ក៏ដូចជាការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់អ្នកផ្តល់សេវាថែទាំព្យាបាល អ្នកឯកទេសមន្ទីរពិសោធន៍ រួមទាំងការផ្គត់ផ្គង់នូវឱសថ និង សម្ភារៈពេទ្យទៅតាមប្រភពធនធានដែលមាន ។

## តើអ្វីជាជំងឺតាឡាសសេមី

តាឡាសសេមី [thalassemia] ជាប្រភេទជំងឺពន្ធុនៃការផលិតអេម៉ូក្លូប៊ីន ។ វាជាជំងឺ តំណពូជតាមបែប autosomal recessive ហើយមានអត្រាខ្ពស់នៅតំបន់អាស៊ីប៉ែកអាគ្នេយ៍នេះ ។

## ភាពខ្វិនថយខាងបរិមាណក្នុងការធ្វើសំយោគអេម៉ូក្លូប៊ីន ~ ជំងឺតាឡាសសេមី

ជំងឺតាឡាសសេមីជាប្រភេទជំងឺតំណពូជមួយក្រុម ដែលមានលក្ខណៈផ្សេងៗគ្នានៃការធ្វើសំយោគមិនប្រក្រតីរបស់អេម៉ូក្លូប៊ីន ដែលជាលទ្ធផលធ្វើអោយមានការថយចុះ ឬ បាត់ មួយ ឬ ច្រើននៃខ្សែក្លូប៊ីន (globin chain) របស់អេម៉ូក្លូប៊ីន។ យោងទៅតាមកំរិតខុសភ្លាត់នៃសំយោគខ្សែក្លូប៊ីន គេចែកចេញជា $\alpha$, $\beta$, $\delta$ និង $\gamma$ តាឡាសសេមី។

គេចែកចេញក្រុមធំៗដូចតទៅ:

**បែតតា តាឡាសសេមី** ($\beta$ – thalassemia)

លក្ខណៈរបស់វាគឺការចុះថយ($\beta^+$) ឬ អវត្តមាន ($\beta^o$) នៅក្នុងសំយោគខ្សែបែតតា ($\beta$-chains)។ ហេតុដូចនេះ គេឃើញមានតែការសំយោគរបស់ HbA មួយមុខគត់ដែលខូចខាត ដែលជាបច្ច័យដល់ការកើនឡើងនៃសំយោគរបស់ Hb F និង/ឬ Hb A2 ដោយមិនពាក់ព័ន្ធដល់ Hb A។

Heterozygous state ជា $\beta^+$ឬ $\beta^o$ thalassemia trait (ដែលគេចាត់ទុកថាជាអ្នកផ្ទុក ) ហើយនៅពេលនោះអេម៉ូក្លូប៊ីនស្ថិតនៅក្នុងកំរិតធម្មតា។ Homozygous state របស់ $\beta^+$ thalassemia ($\beta^+\beta^+$) និង compound heterozygous state ($\beta^+\beta^o$) ជាបែតតាតាឡាសសេមីកំរិតមធ្យម–ហើយ អេម៉ូក្លូប៊ីនស្ថិតនៅក្នុងកំរិតពី 7-10 ក្រ/ដល។

Homozygus state របស់ $\beta^o$ - thalassemia ($\beta^o\beta^o$) ជាបែតតាតាឡាសសេមីកំរិតធ្ងន់ ជាមូលហេតុនៃភាពស្លេកស្លាំងធ្ងន់ធ្ងរ ដែលអាស្រ័យដោយការបញ្ចូលឈាម។

**អាល់ហ្វា តាឡាសសេមី ($\alpha$– thalassemia)**

លក្ខណៈរបស់វាគឺការចុះថយសំយោគខ្សែអាល់ហ្វា ($\alpha$-chains) ដែលជាលទ្ធផលធ្វើឱ្យមានវិបត្តិ ទៅលើសំយោគរបស់អេម៉ូក្លូប៊ីនធម្មតាទាំងអស់។ ហេតុការណ៍នេះបណ្តាលឱ្យមានការកើនឡើងលើសពីធម្មតានៃសំយោគខ្សែបែតតា និង ខ្សែអាល់ហ្វា ($\beta$- and $\gamma$ - chains) ដោយមិនពាក់ព័ន្ធដល់ការ ចុះថយនៃសំយោគរបស់ខ្សែអាល់ហ្វាឡើយ ។ ការនេះបង្កឱ្យកកើតជាចតុភាគ (tetramers) ថ្មីមួយដោយគ្មានសមាសភាគនៃ ខ្សែអាល់ហ្វា ។

Hb Bart = $\gamma4$
Hb H = $\beta4$
បុគ្គលធម្មតាមានពន្ធុអាល់ហ្វាដែលមានមុខងារធម្មតាចំនួន ៤ (4 functional $\alpha$ globin genes) សំគាល់ដោយ $\alpha\alpha/\alpha\alpha$ ។

បុគ្គលណាដែលមានពន្ធុអាល់ហ្វាដែលមានមុខងារធម្មតាតែ ២ ឬ ៣ ហើយមាន អេម៉ូក្លូប៊ីនក្នុងកំរិតធម្មតា ត្រូវបានចាត់ថ្នាក់តាមលក្ខណៈអាការៈរោគជាអាល់ហ្វាតាឡាសសេមីកំរិតស្រាល ($\alpha$-thalassemia trait) សំគាល់ដោយ $\alpha$-thal 1 (--/$\alpha\alpha$ ) ឬ $\alpha^{o}$-thalassemia និង $\alpha$-thal 2 (-$\alpha$/$\alpha\alpha$) ឬ $\alpha^{+}$ -thalassemia ។

Homozygous $\alpha^{+}$-thalassemia សំគាល់ដោយ (-$\alpha$/-$\alpha$) និងមានអេម៉ូក្លូប៊ីនក្នុងកំរិតធម្មតា។ បុគ្គលណាដែលទទួលបាននូវតំណពូជពន្ធុអាល់ហ្វាដែលមានមុខងារធម្មតាតែ ១ គត់ ត្រូវបានសំគាល់ដោយ (--/-$\alpha$) ហើយនេះជាជំងឺអេម៉ូក្លូប៊ីន H ដោយមានភាពស្លេកស្លាំងកំរិតមធ្យម ឬ ធ្ងន់ធ្ងរដែលតំរូវអោយបញ្ចូលឈាមម្តងម្កាល។

ចំពោះអ្នកដែលមានតំណពូជពន្ធុអាល់ហ្វាដែលមិនមានមុខងារធម្មតា (no functional $\alpha$-genes) ត្រូវបានសំគាល់ដោយ (--/--) ដែលមានស្ថានភាពមិនអាចរស់រានបានឡើយ ហើយត្រូវគេស្គាល់ថាជា Hb Barts hydrops fetalis (ទារកហើមដោយសារមានជាតិទឹកច្រើន អាចស្លាប់មុនពេលសំរាល ឬរយៈពេលខ្លី ក្រោយសំរាល)។

កំរិតធ្ងន់ធ្ងររបស់ភាពស្លេកស្លាំងនៃជំងឺតាឡាសសេមី អាស្រ័យទៅនឹងភាពរួមផ្សំគ្នាទាំងពីរ រវាងកត្តាបណ្តុំពន្ធុ (polygenic factor) និង កត្តាដែលទទួលបានពីខាងក្រៅ។ ចង្កោមរោគសញ្ញារបស់តាឡាសសេមីកើតឡើងដោយសារប្រសិទ្ធិភាពនៃការផលិតគ្រាប់ឈាមក្រហមចុះខ្សោយ រួម និង រយៈពេលរស់នៅរបស់គ្រាប់ឈាមក្រហមចុះថយ បណ្តាលមកពីភាពមិនស្មើគ្នានៃសំយោគខ្សែក្លូប៊ីន (globin chain)។ កត្តាពន្ធុ ឬ កត្តាដែលទទួលបានពីក្រៅផ្សេងៗទៀតដែលកាត់បន្ថយកំរិតអតុល្យភាពខ្សែក្លូប៊ីន អាចជួយបន្ថយភាពធ្ងន់ធ្ងរនៃរូបភាពគ្លីនិក។

ជំងឺតំណពូជ ដែលមានកោសិកាឈាមក្រហមរាងទ្រវែង ( ovalocytosis ), កង្វះជាតិដែក និង កង្វះអាស៊ីតផូលិកកាន់តែធ្វើឱ្យសភាពគ្លីនិកធ្ងន់ធ្ងរ។ នៅក្នុងករណីជំងឺ β-thalassaemia វត្តមានរបស់ $\alpha$-thalassaemia និង កំណើនសំយោគរបស់ Hb F ជួយឱ្យ β-thalassaemia បានប្រសើរឡើង។

## ភាពខ្វិនថយខាងគុណភាពក្នុងការធ្វើសំយោគអេម៉ូក្លូប៊ីន ៱ ជំងឺអេម៉ូក្លូប៊ីន

ជំងឺអេម៉ូក្លូប៊ីនរោគវិទ្យា ជាជំងឺមួយដែលបណ្តាលមកពីរចនាសម្ព័ន្ធមិនធម្មតានៃសំយោគរបស់អេម៉ូក្លូប៊ីនដែលធ្វើអោយថយចុះនូវបរិមាណនៃការសំយោគអេម៉ូក្លូប៊ីនទាំងនេះ ។ ទាំងនេះបណ្តាលមកពីដំណើរការមិនធម្មតារបស់ mRNA ឬ ដោយសារភាពមិនស្ថិតស្ថេររបស់ខ្សែក្លូប៊ីនមិនធម្មតា (globin chain) ។ ភាគច្រើននៃជំងឺអេម៉ូក្លូប៊ីនដែលស្តែងចេញជាអាការៈរោគ ច្រើនបណ្តាលមកពីភាពផ្លាស់ប្តូររបស់អាមីណូអាស៊ីត (single amino acid ) ទៅក្នុង ខ្សែអាល់ហ្វា ឬ ខ្សែបែតតា ។

គេបានសិក្សាទៅឃើញថាមានជាង ៩០០ ប្រភេទនៃអេម៉ូក្លូប៊ីនពេញវ័យដែលមានបំរែបំរួល។

## អេម៉ូក្លូប៊ីន E

អាស៊ីតក្លុយតាមីក (glutamic acid) មួយរបស់ខ្សែបែតតា (a mutation in codon 26) ត្រូវបានជំនួស ដោយ lysine ។ នៅក្នុងទំរង់ heterozygous state កំរិត Hb E មានពី ២៥-៣០% រួមជាមួយនឹងកំរិត ធម្មតារបស់អេមូក្លូប៊ីន ។

នៅក្នុងទំរង់ homoozygous state កំរិតវា (Hb E levels) មានពី ៩០-១០០% ដែលអាចបណ្តាលឱ្យមាន ភាពស្លេកស្លាំងកំរិតស្រាល ។ ទោះជាយ៉ាងណាក៏ដោយ Hb E នៅជាមួយនឹង β-thalassemia អាច បណ្តាលឱ្យមានភាពស្លេកស្លាំងកំរិត មធ្យមទៅធ្ងន់ធ្ងរ ឬ ល្មមទៅខ្លាំង ។

ភាពស្មុគស្មាញនៃអន្តរកម្មរបស់ Hb E ជាមួយនឹង α និង β-thalassemia បង្កើត ឱ្យមាន phenotypes មួយ ដែលបង្កឱ្យមានជាង ៦០ កន្សោម រោគសញ្ញាតាឡាសសេមីផ្សេងៗគ្នា ។

## អេម៉ូក្លូប៊ីន Constant Spring (Hb CS)

Hb CS កើតឡើងពីការខូចខាតចំណុចបញ្ចប់ទី១៤២ (termination codon 142 defect) នៅក្នុង α2 globin gene ។ ជាលទ្ធផល វាធ្វើឱ្យ មានការកកើតនៃ α globin chain ដែលមានបន្ថែម ១៣១ អាមីណូអាស៊ីត ។ ខ្សែ mRNA វែង ហើយមិនមានស្ថេរភាព ហើយជាលទ្ធផល វាធ្វើឱ្យមានការសំយោគ មិនប្រក្រតីនូវខ្សែអាល់ហ្វា រួមជាមួយការកើនឡើងនូវការផលិត Hb Barts ។

នៅក្នុងទំរង់ heterozygous state កំរិត Hb CS តិចជាង 1% រួមជាមួយកំរិតធម្មតារបស់អេមូក្លូប៊ីន ។ នៅក្នុងទំរង់ homozygous state កំរិត Hb CS មានពី ១- ៦ % ហើយភាពស្លេកស្លាំងស្ថិតនៅក្នុងកំរិត ស្រាល ។ អន្តរកម្មរបស់ Hb CS ជាមួយ $\alpha^{0}$-thalassemia បង្កើតបានជាជំងឺ Hb CS-H ហើយភាពស្លេក ស្លាំងមានកំរិតពីមធ្យមទៅធ្ងន់ធ្ងរ ។

អន្តរកម្មរវាងប្រភេទផ្សេងៗនៃតាឡាសសេមី និង អេម៉ូក្លូប៊ីនមិនប្រក្រតីមានភាពស្មុគស្មាញ ។ ប្រសិនត្រូវ ការពត៌មានបន្ថែម គេអាចរកបានតាមការបោះពុម្ពផ្សាយដោយសហព័ន្ធតាឡាសសេមីអន្តរជាតិ តាមគេហ៍ ទំព័រ www.thalassaemia.org.cy

## លក្ខណៈគ្លីនិកនៃជំងឺតាឡាសសេមីដែលមិនបានទទួលការព្យាបាល

ទារកដែលមាន homozygous β thalassaemia ជាដំបូងគ្មានរោគសញ្ញាអ្វីឡើយ ព្រោះថា Hb ចំបង ពេលកើតពីផ្ទៃម្តាយ គឺ fetal hemoglobin (HbF) ។ ជាលក្ខណៈរូបវិទ្យា, HbF ត្រូវប្តូរទៅជា HbA

ដូចនេះ HbA មានកាន់តែច្រើននៅអាយុចាប់ពី ៤ - ៦ ខែទៅ ដែលពេលនោះហើយកុមារដែលមានជំងឺ thalassaemia major អាចចេញជារោគសញ្ញា ។

តាមលក្ខណៈគ្លីនិក, រោគសញ្ញាបង្ហាញតាមបែបផ្សេងៗ ដូចជា :

- ថយការបៅដោះ
- មិនសួវធំធាត់
- ស្លេកស្លាំង
- ឧស្សាហ៍មានការបង្ករោគ (Infections)

បើមិនបានព្យាបាលទេ, វាវិវត្តន៍បន្តិចម្តងៗទៅជាស្លេកស្លាំងខ្លាំង (progressive anemia), អណ្តើក-ថ្លើមរីកធំ (hepato-splenomegaly), រាង្គកាយទ្រុឌទ្រោម (metabolic stress), ការសំយោគគោលិកាឈាមក្រហមដោយខួរឆ្អឹងគ្មានប្រសិទ្ធិភាព ជាហេតុធ្វើអោយឆ្អឹងស្តើង និង ប្រែប្រួលទំរង់ ។ បើមិនព្យាបាលទេ, កុមារដែលមានជំងឺ (β) thalassaemia major អាចនឹងស្លាប់មុនអាយុប្រាំឆ្នាំដោយរោគខ្សោយបេះដូង ឬ ការបង្ករោគ ។

## ការវិភាគរករោគ និង ការការពារ / Screening and Prevention

ដើម្បីរកអោយឃើញថាជាអ្នកផ្ទុក (β) thalassaemia, នោះការវិភាគរករោគមុនពេលបង្កកំណើត (antenatal screening) និង ក្នុងចំណោមប្រជាជនទូទៅ ជាបច្ចេកទេសងាយស្រួល ហើយអស់តំលៃថោក ។ ការរកអោយឃើញថាឪពុកម្តាយជាអ្នកផ្ទុក ជាទូទៅចំពោះម្តាយ បន្ទាប់មកតេស្តឪពុក ការនេះអាចអោយគេរកឃើញថាជា **គូស្រករប្រឈម** (at-risk couples) ដែលអាចនឹងមានកូនដែលមានជំងឺ ។ ក្រោយពីទទួលបានការប្រឹក្សារួច, ពួកគេអាចទទួលពត៌មានអំពីជំរើសនៃការធ្វើរោគវិនិច្ឆ័យទារកក្នុងផ្ទៃ និង ការបញ្ឈប់ផ្ទៃពោះបើទារកនោះមានជំងឺ ។

នៅប្រទេសកម្ពុជា, ជំងឺ Hb ជាប្រភេទជំងឺពន្ធុទោលដែលសំបូរជាងគេ (អ្នកផ្ទុកត្រូវបានប្រមាណថាប្រហែល ៣០% ទៅ ៥០% នៃប្រជាជនទូទៅ) ហើយស្តែងចេញជារោគសញ្ញាគ្លីនិកធ្ងន់ធ្ងរ ។ ដូចនេះមានកម្មវិធីការពារ (prevention programme) ជាការសំខាន់ ព្រោះថាវាជាជំងឺដែលមិនអាចព្យាបាលអោយជាបាន ហើយធ្វើអោយអ្នកជំងឺធ្លាក់ក្នុងភាពអស់សង្ឃឹមព្រោះតែការព្យាបាលមានតំលៃខ្ពស់ និង លំបាកក្នុងការផ្តល់ការព្យាបាលអោយបានពេញចិត្តដល់អ្នកជំងឺណាស់ ដែលការនេះបង្កើតជាបន្ទុកចំពោះអ្នកជំងឺ ចំពោះក្រុមគ្រួសារ និង ចំពោះសេវាសុខាភិបាលជាតិ ។

តាមពិត វាជាសិទ្ធិរបស់បុគ្គល ឬ គូស្រករ ត្រូវទទួលបានពត៌មាន អំពីគ្រោះប្រឈមនឹងជំងឺពន្ធុដែលអាចប៉ះពាល់ចំពោះពួកគេ ។ ទាំងអស់នេះ វាជាសិទ្ធិរបស់ពួកគេ ដែលត្រូវទទួលពត៌មានអំពីជំរើសទាក់ទងនឹងគ្រោះប្រឈមទាំងនេះ ។ យ៉ាងណាក៏ដោយ, លទ្ធភាពដើម្បីទទួលបានពត៌មានអំពីជំរើស វាអាស្រ័យនឹងកត្តាមួយចំនួន :

- **ការអប់រំសុខភាព** (Health education)

សេវាថែទាំសុខភាពបឋមត្រូវមានបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលដើម្បីជួយអោយមានប្រសិទ្ធិភាពដល់ការការពារជំងឺពន្ធុដែលត្រូវបានធានាអោយប្រាកដថាគូស្រករប្រឈម (at-risk couple) នឹងសំរេចបានគោលបំណង ហើយទទួលបានការថែទាំព្យាបាលប្រកបដោយសមធម៌ ។

- **ការវិភាគរករោគ** (Screening), ដែលគួរតែមានអោយបានឆាប់ចំពោះជីវិតគូស្រករដែលស្ថិតក្នុងវ័យបន្តពូជដើម្បីអោយពួកគេការពារតាំងពីដំបូង (primary prevention) ។

  មានលទ្ធភាព ២ បែបដើម្បីរកអ្នកផ្ទុកបែតតាតាឡាសសេមី (β - thalassemia carrier) :

  ១. ការវិភាគបឋម : កំណត់ red cell indices ជាមុនសិន, រួចធ្វើតំណាក់កាលបន្ទាប់គឺ hemoglobin analysis (Hb typing) ចំពោះតែបុគ្គលណាដែលមាន MCV និង/ឬ MCH ថយចុះ ។

  ២. ការវិភាគពេញលេញ : ធ្វើព្រមគ្នាតែម្តងតាំងពីដំបូង គឺ កំណត់ red cell indices, hemoglobin analysis (Hb typing) និង $HbA_2$ ចំពោះបុគ្គលទាំងអស់ ។ តាមអនុសាសន៍, ត្រូវធ្វើការវិភាគពេញលេញតែម្តងចំពោះក្រុមប្រជាពលរដ្ឋដែលសំបូរទាំងពីរប្រភេទ អាល់ហ្វា និង បែតតា តាឡាសសេមី និងចំពោះក្រុមប្រជាពលរដ្ឋដែលមានអន្តរកម្មរវាង អាល់ហ្វា និង បែតតា តាឡាសសេមី ជាហេតុធ្វើអោយ red cell indices មានភាពធម្មតា ហើយការនេះអាចនាំអោយយើងធ្វើរោគវិនិច្ឆ័យខុស ។

- **ការប្រឹក្សាយោបល់ផ្នែកពន្ធុ** (Genetic counselling)

  ការប្រឹក្សាផ្នែកពន្ធុ (genetic counselling) មានភាពស្មុកស្មាញបំផុត ហើយមានទិដ្ឋភាពសង្គមដ៏សំខាន់ចំពោះការការពារ ។ វាមិនអាចញែកចេញពីការធ្វើរោគវិនិច្ឆ័យផ្នែកពន្ធុ (genetic diagnosis) បានឡើយ ក្នុងបំណងកុំអោយយល់ខុសអំពីមូលហេតុនៃជំងឺផ្នែកពន្ធុ ដោយផ្តល់ពត៌មានអោយបានត្រឹមត្រូវ និងក្នុងបំណងលើកកំពស់ការគ្រប់គ្រងរបស់ប្រជាពលរដ្ឋចំពោះសុខភាពក្រុមគ្រួសាររបស់ពួកគេ ដោយផ្តល់ពត៌មានដល់ពួកគេនូវប្រភពដែលមានសំរាប់ធ្វើរោគវិនិច្ឆ័យ សំរាប់ការព្យាបាល និង សំរាប់ការការពារ ។

  ការប្រឹក្សាផ្នែកពន្ធុ ត្រូវបានគេអោយនិយមន័យដូចតទៅ : **ជាដំណើរពិគ្រោះយោបល់ដែលអ្នកជំងឺ ឬ សាច់ញាតិដែលប្រឈមនឹងគ្រោះកើតជំងឺដែលអាចឆ្លងតពូជ ត្រូវបានផ្តល់ដំបូន្មានអំពីផលវិបាកនៃជំងឺ, ហើយនឹងលទ្ធភាពវិវត្តន៍ និង ការបញ្ជូនវាតាមតំណពូជ, ព្រមទាំងអំពីមធ្យោបាយដែលអាចការពារបាន ឬ ធ្វើអោយប្រសើរបាន ។**

  តាមនិយមន័យនេះ ចាំបាច់ត្រូវមាន :

  - ការធ្វើរោគវិនិច្ឆ័យអោយបានត្រឹមត្រូវចំពោះសមាជិកក្រុមគ្រួសារ ។
  - ការពន្យល់អំពីសភាព និង បុរេនិមិត្ត (prognosis) នៃជំងឺ, លទ្ធភាពព្យាបាលដែលមាន ហើយមាននៅទីណា ។

- ការប៉ាន់ប្រមាណគ្រោះប្រឈមនឹងជំងឺពន្ធុរបស់ឪពុកម្តាយ និង សមាជិកក្រុមគ្រួសារ ។ ការនេះតម្រូវឱ្យដឹងគួរពង្សាវលី (family tree) ។ គេអាចធ្វើតេស្តស្រាវជ្រាវចំពោះសមាជិកក្រុមគ្រួសារដទៃៗទៀតដែរ ។
- ការប្រាប់អោយដឹងអំពីគ្រោះប្រឈមនឹងជំងឺពន្ធុ និង ជំរើសដើម្បីជៀសវាងវា រួមមានឱកាសរបស់ឪពុកម្តាយ និង សមាជិកក្រុមគ្រួសារដទៃៗទៀតដែលនឹងបញ្ជូនជំងឺទៅអោយកូនៗរបស់ពួកគាត់ ហើយនិងការពន្យល់អំពីគ្រោះប្រឈម ។ ជំរើសដើម្បីជៀសវាងការប៉ះពាល់ដល់កូនៗក្រោយទៀតក៏ត្រូវពន្យល់ដែរ រួមមានបច្ចេកទេសក្នុងការធ្វើរោគវិនិច្ឆ័យទារកក្នុងផ្ទៃ និង បញ្ហារួមផ្សំ, គ្រោះប្រឈមនឹងការភាន់ច្រឡំ និង ផលវិបាក ។
- ការគាំទ្របុគ្គល ឬ គូស្រករក្នុងការសំរេចចិត្តថាវាជាការត្រឹមត្រូវសំរាប់ពួកគេ ។
- លទ្ធភាពអាចទំនាក់ទំនងបានយូរអង្វែង ព្រោះថាប្រជាពលរដ្ឋដែលមានគ្រោះប្រឈម ជាញឹកញាប់ត្រូវការប្រឹក្សាយោបល់ និង ការគាំទ្រចំណុចខ្លះៗក្នុងជីវិតរបស់ពួកគេ ។

សំរេចបានតំរូវការខាងលើនេះ ត្រូវការអ្នកជំនាញដែលមានចំណេះដឹងខាងពន្ធុ បានទទួលការបណ្តុះបណ្តាលជំនាញខាងប្រឹក្សាយោបល់ មានពេលវេលាគ្រប់គ្រាន់ មានសមត្ថភាពខាងការសន្ទនា និង ដោយមានជំនួយពីអ្នកឯកទេសខាងពន្ធុវេជ្ជសាស្ត្រ (medical geneticist) ឬ អ្នកប្រឹក្សាផ្នែកពន្ធុដែលបានទទួលការបណ្តុះបណ្តាល (trained genetic counselor) ។

- **រោគវិនិច្ឆ័យទារកក្នុងផ្ទៃ** (Prenatal diagnosis), ដែលបង្កើនជំរើសដល់គូស្រករ ។ ការនេះអាចធ្វើបាន ដោយការពិនិត្យ**សាច់សុក** (Chorionic Villous Sampling / CVS) ពេលមានផ្ទៃពោះបាន ៩ ទៅ ១១ អាទិត្យ, ដោយការពិនិត្យ **ទឹកភ្លោះ** (Amniocentesis) ពេលមានផ្ទៃពោះបាន ១៥ អាទិត្យ ឬ ដោយការពិនិត្យ **ឈាមទងសុក** (Cordocentesis) ពេលមានផ្ទៃពោះបាន ១៨ អាទិត្យ។ តេស្តទាំងនេះមិនទាន់ធ្វើបាននៅប្រទេសកម្ពុជាយើងទេ ។

## ក្រុមលើកទឹកចិត្ត និង ឧបត្ថម្ភគាំទ្រ / Support Group

ត្រូវការអ្នកផ្តល់សេវាសង្គមនៅនឹងតំបន់ (local social workers) ដើម្បីជួយគាំទ្រស្មារតី លើកទឹកចិត្តដល់អ្នកជំងឺ និង ក្រុមគ្រួសារ ។

បច្ចុប្បន្ននេះ មានសមាគមតាឡាសសេមីនៅកម្ពុជាហើយ (Cambodia Thalassemia Association / CTA) ។ បេសកកម្មរបស់សមាគមគឺធ្វើការឆ្ពោះទៅគោលដៅមួយដែលគ្រប់អ្នកជំងឺតាឡាសសេម៉ីនៅក្នុងប្រទេសកម្ពុជា ត្រូវតែទទួលបានដូចគ្នាក្នុងការថែទាំសុខភាពប្រកបដោយគុណភាព ។

# Approach to an Anemic Child
## ជំហានក្នុងការពិនិត្យកុមារស្លេកស្លាំង

សង្ស័យជា Anemia

↓

- ប្រវត្តិជំងឺ / History
- ការពិនិត្យអ្នកជំងឺ / Physical Examination
- ការវិភាគឈាមស្រាវជ្រាវបឋម / Preliminary Investigations : CBC, red cell indices, RDW, reticulocyte count, blood film

↓

តើមានបង្ហាញជា generalized lymphadenopathy និង / ឬ hepatosplenomegaly ?

**មាន**

### រោគវិនិច្ឆ័យផ្សេងៗ

- ជំងឺមហារីកឈាម (Acute / chronic leukemia)
- Chronic hemolytic anemia :
  - **Thalassemia** (សូមអាន មគ្គុទ្ទេសក៍សំរាប់ថែទាំព្យាបាល កុមារមានជំងឺតាឡាសេមី)
  - Hereditary spherocytosis
  - Hereditary elliptocytosis
- ជំងឺមហារីក ដូចជា lymphoma
- Chronic infection ដូចជា ជំងឺរបេង

**គ្មាន**

### រោគវិនិច្ឆ័យផ្សេងៗ

- ការបាត់បង់ឈាមថ្មីៗ / ហូរឈាម
- កង្វះជាតិដែក (Fe deficiency)
- កង្វះជាតិ Folic acid
- កង្វះវីតាមីន $B_{12}$
- Acute hemolytic anemia :
  - G6PD deficiency
  - Paroxysmal Nocturnal Hemolysis
  - Autoimmune disease
  - ABO or other blood group incompatibility
  - Acute infection ដូចជា ជំងឺគ្រុនចាញ់
  - បណ្តាលមកពីការប្រើឱសថផ្សេងៗ
- អសមត្ថភាពខួរឆ្អឹង (Bone marrow failure)
  - Aplastic anemia
  - Fanconi's anemia
  - Diamond-Blackfan anemia
- ផ្សេងៗទៀត
  - Hypothyroidism
  - Chronic renal failure

## បំរែបំរួលនៃ **CBC indices** ទៅតាមអាយុ [1]

| អាយុ | Hb (g/dl) | RBC ($x10^{12}/l$) | MCV (fl) |
|---|---|---|---|
| ទើបនឹងកើត | 14.9 – 23.7 | 3.7 – 6.5 | 100 – 135 |
| 1 – 2 ខែ | 9.4 – 13.0 | 3.1 – 4.3 | 84 – 105 |
| 3 – 12 ខែ | 11.3 – 14.1 | 4.1 – 5.3 | 71 – 85 |
| 2 – 5 ឆ្នាំ | 11.5 – 13.5 | 3.9 – 5.3 | 75 – 87 |
| 6 – 12 ឆ្នាំ | 11.5 – 15.5 | 4.0 – 5.2 | 77 – 95 |
| 13 – 18 ឆ្នាំ ស្ត្រី | 12.0 – 16.0 | 4.1 – 5.1 | 78 – 95 |
| 13 – 18 ឆ្នាំ បុរស | 13.0 – 16.0 | 4.5 – 5.3 | 78 – 95 |

# ការវិភាគស្រាវជ្រាវជាមូលដ្ឋានដែលត្រូវធ្វើចំពោះអ្នកជំងឺថ្មី

(ចំណាំ : ដើម្បីទទួលបានរោគវិនិច្ឆ័យត្រឹមត្រូវ, សំខាន់គេត្រូវធ្វើតេស្តទាំងនេះអោយបានមុន ការបញ្ចូលឈាម ឬ យ៉ាងហោចណាស់ក៏ ៣ ខែក្រោយការបញ្ចូលឈាមចុងក្រោយដែរ)

- Complete blood count (CBC) និង peripheral blood film (ក្នុងករណីច្បាស់លាស់, កំរិត Hb គួរតែ < 7g/dl)
- Hb typing / Hb Electrophoresis (ធ្វើបាននៅមន្ទីរពេទ្យកុមារជាតិ និង វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា)
- Serum Ferritin
- តេស្តមុខងារថ្លើម (liver function test)
- វិភាគរកការបង្ករោគ (infection) - HIV, Hepatitis B & C, and Syphilis (មុនពេលបញ្ចូលឈាមលើកដំបូង)
- គួរធ្វើការវិភាគឈាមស្រាវជ្រាវតាមរយៈ Hb Electrophoresis គ្រប់សមាជិកគ្រួសារទាំងអស់ ដើម្បីផ្តល់ការប្រឹក្សាផ្នែកពន្ធុ (genetic counseling)
- Red Cell Phenotyping (ជាការល្អ) មុនពេលបញ្ចូលឈាមលើកដំបូង
- DNA analysis / Genotyping (អាស្រ័យតាមការសំរេចចិត្តរបស់លោកអ្នក) - គេធ្វើវាដើម្បីអះអាងរោគវិនិច្ឆ័យនៃបំរែបំរួល Hb ផ្សេងៗទៀត (Hb variants) ហើយត្រូវបានគេប្រើក្នុងការធ្វើរោគវិនិច្ឆ័យទារកក្នុងផ្ទៃ (prenatal diagnosis) និង ការរករោគវិនិច្ឆ័យចំពោះអ្នកផ្ទុក (បច្ចេកទេសនេះធ្វើបាននៅតែវិទ្យាស្ថានប៉ាស្ទ័រ) ។

# ការបកស្រាយលទ្ធផល Hb electrophoresis

1. Abnormal Hb typing in ß-thalassemia :
   - HbA ថយចុះ ឬ គ្មាន
   - HbF កើនឡើង
   - HbA2 កើនឡើង
2. Abnormal Hb typing in E/ß-thalassemia :
   - HbA ថយចុះ ឬ គ្មាន
   - Hb F ប្រែប្រួល
   - HbA2 ប្រែប្រួល
   - HbE មាន
3. Abnormal Hb typing in α-thalassemia :
   - HbA ថយចុះ
   - HbF ប្រែប្រួល
   - HbA2 ថយចុះ
   - HbH មាន
   - Hb Barts មាន
   - Hb Constant Spring (មានក្នុងករណីខ្លះ)

ភាពមិនធម្មតាផ្សេងៗទៀតនៃ Hb's អាចនឹងជួបប្រទះដែរ ឬក៏មានការផ្គុំគ្នានៃ Hb's ទាំងអស់ខាងលើនេះ ។

# ការថែទាំព្យាបាល

ការបញ្ចូលឈាមជាទៀងទាត់ និង ការព្យាបាលកំចាត់ជាតិដែក ទាំងនេះជាគោលចំបងនៃការព្យាបាលចំពោះអ្នកជំងឺតាឡាសសេមីដែលអាស្រ័យដោយការបញ្ចូលឈាម (patient with transfusion dependent thalassemia) ។

## 1. ការបញ្ចូលឈាម / Blood Transfusion

### Beta - Thalassemia major

**តើពេលណាចាប់ផ្តើមបញ្ចូលឈាម ?**

- បន្ទាប់ពីបានវិភាគឈាមរួចរាល់ដើម្បីធ្វើរោគវិនិច្ឆ័យ ។
- Hb < 7g/dl លើសពី ២ អាទិត្យ (ក្នុងករណីគ្មានកត្តាបង្ករផ្សេងទៀត ដូចជា Infection)
- Hb > 7g/dl ក្នុងករណីមានការលូតលាស់យឺតយ៉ាវ, បំរែបំរួលឆ្អឹង, រីកធំអណ្តើក-ថ្លើម ។
    - អ្នកជំងឺ HbE/β thalassaemia អាចមានកំរិត Hb ថេររវាង 6 - 7g/dl ដោយមិនបញ្ចូលឈាម ។
    - មុនបញ្ចូលឈាមដំបូង ត្រូវចាក់ថ្នាំបង្ការលាកថ្លើមបេអោយបានគ្រប់គ្រាន់សិន ។
    - ត្រូវប្រាកដថាឈាមអ្នកបរិច្ចាក វាស៊ីគ្នានឹងឈាមអ្នកជំងឺ ជាពិសេស Rh (D) antigens ។

**គោលដៅនៃការបញ្ចូលឈាម ?**

- ដើម្បីរក្សាកំរិត Hb រាល់ពេលមុនការបញ្ចូលឈាម (pre-transfusion) : 9.5 – 10.5 g/dl
- មិនគួរតំឡើងកំរិត Hb ក្រោយការបញ្ចូលឈាមអោយលើសពី 14 g/dl
- បច្ចុប្បន្ននេះ, ជាអនុសាសន៏គឺត្រូវរក្សាកំរិតមធ្យមនៃ Hb អោយនៅចន្លោះ 12 – 12.5 g/dl ដើម្បីជួយដល់សកម្មភាពប្រចាំថ្ងៃធម្មតានៃរាងកាយ និង ការលូតលាស់ធំធាត់, អាចបំបាត់កង្វះអុកស៊ីហ្សែនរ៉ាំរ៉ៃ និង កាត់បន្ថយការរីកធំនៃខួរឆ្អឹង (compensatory marrow hyperplasia) ។

**គំលាតពេលនៃការបញ្ចូលឈាម ?**

- ជាទូទៅរវាង ៤ អាទិត្យម្តង
- គំលាតពេលនេះប្រែប្រួលពីអ្នកជំងឺម្នាក់ទៅម្នាក់ ( ជាមធ្យម : ២ - ៦ អាទិត្យ) ។
- បរិមាណឈាមក្រហម (packed red cells) ត្រូវបញ្ចូល 20 ml/kg (អតិបរមា) ដោយប្រើពេល ៤ ម៉ោង ។

*ក្នុងករណីមានជំងឺខ្សោយបេះដូង (cardiac failure) ឬ Hb < 5g/dl ត្រូវប្រើបរិមាណឈាមក្រហមក្នុងកំរិតទាប (< 5ml/kg) ដោយបញ្ចូលយឺតៗ 4 ម៉ោង រួមជាមួយនឹងការប្រើថ្នាំ furosemide 1 mg/kg (ច្រើនបំផុត 20 mg) ។*

ជាអនុសាសន៍សំរាប់អ្នកជំងឺ, គួរបញ្ចូលឈាមដែលជាគ្រាប់ឈាមក្រហមច្រោះយកគោលិកាឈាមសចេញ (leucodepleted packed cells / LPRC) ឬ គ្រាប់ឈាមក្រហមមិនច្រោះ (packed red cells / PRC) ដែលបានរក្សាទុករយៈពេលតិចជាង 1 អាទិត្យ ហើយប្រើប្រាស់ឧបករណ៍ចំរោះ (filters) ពេលចាប់បញ្ចូលឈាមដោយច្រោះយកគោលិកាឈាមសចេញដើម្បីការពារប្រតិកម្មអោយក្តៅខ្លួន (non-hemolytic febrile reactions) ។

នៅប្រទេសកម្ពុជាបច្ចុប្បន្ននេះ គេរកបានតែប្រភេទឈាម PRC ហើយរកបាននៅមជ្ឈមណ្ឌលជាតិផ្តល់ឈាម និង នៅតាមមន្ទីរពេទ្យបង្អែកភាគច្រើន, ហើយមិនទាន់មាន LPRC នៅឡើយទេ ។ បើមានតែឈាមទាំងមូល (whole blood) នៅតាមមន្ទីរពេទ្យបង្អែក, គេត្រូវទុកឈាមនោះមួយយប់នៅសីតុណ្ហភាព ៤°C នោះប្លាស្មានឹងអណ្តែតឡើង ឬ គេប្រើឧបករណ៍កៀបបញ្ចេកឈាមដែលមន្ទីរពិសោធន៍នៃមជ្ឈមណ្ឌលជាតិផ្តល់ឈាមភាគច្រើនគួរតែមាន ។

### Beta - Thalassemia intermedia

វាជាប្រភេទទំរង់ស្រាលនៃ β- តាឡាសសេមី ហើយភាពស្លេកស្លាំងបង្ហាញឡើងយឺត១ ជាទូទៅក្រោយអាយុ ២ ឆ្នាំ ដោយក៏រិត ≥ Hb 8g/dl ។ ចំពោះអ្នកជំងឺទាំងនេះមានភាពធ្ងន់ធ្ងរខុស១គ្នាដោយខ្លះឆាប់ចេញរោគសញ្ញា ឯខ្លះទៀតគ្មានរោគសញ្ញារហូតដល់អាយុពេញវ័យ ។ បើពួកគេត្រូវការបញ្ចូលឈាម ជាទៀងទាត់ សូមប្រើរូបមន្តព្យាបាលដូចក្នុងជំងឺបែតតាតាឡាសេមីក៏រិតធ្ងន់ដែរ (β - thalassemia major) ។

### Alpha - Thalassemia (Hb H disease)

ត្រូវបញ្ចូលឈាម តែក្នុងករណីដែល Hb < 7g/dl ឬ មានចេញជារោគសញ្ញាប៉ុណ្ណោះ ។

## 2. ការព្យាបាលកំចាត់ជាតិដែក / Iron Chelation Therapy

ផលវិបាកនៃការលើសជាតិដែករ៉ាំរ៉ៃចំពោះអ្នកជំងឺតាឡាសសេមីអាយុលើសពី ១០ ឆ្នាំ រួមមាន :

- **ផលវិបាកលើក្រពេញអង់ដូគ្រីន** (endocrine glands) - ការលូតលាស់យឺតយ៉ាវ, ក្រពេញវ័យ, ថយចុះមុខងារនៃក្រពេញទីរ៉ូអ៊ីត (hypothyroidism), ថយចុះមុខងារនៃក្រពេញប៉ារ៉ាទីរ៉ូអ៊ីត (hypoparathyroidism) និង ជំងឺទឹកនោមផ្អែម ។
- **បេះដូង** - ចង្វាក់បេះដូងដើរមិនទៀងទាត់, រលាកស្រោមបេះដូង, ខ្សោយបេះដូង ។
- **ថ្លើម** - ក្រិនថ្លើម (liver cirrhosis)

ការនេះចាំបាច់ណាស់ដើម្បីការពារមិនអោយលើសជាតិដែក ។ ឱសថដែលមានប្រសិទ្ធិភាពសំរាប់ពេលបច្ចុប្បន្ននេះ គឺ Deferrioxamine (Desferal®), ជាទំរង់ចាក់ក្រោមស្បែក ។

## តើត្រូវចាប់ប្រើនៅពេលណា ?

- ជាទូទៅ ពេលដែលកុមារអាយុលើសពី 3 ឆ្នាំ ហើយពេលដែល serum ferritin ឡើងលើសពី 1000 ng/ml ដែលតែងតែកើតឡើងបន្ទាប់ពីបញ្ចូលឈាមបាន ១៥ - ២០ ដងឡើងទៅ ។
- មុនចាប់ផ្តើមប្រើ, ត្រូវដឹងពីកំរិត serum ferritin និង ជាតិដែកជាមុនសិន ។ អាចប្រឈមនឹងការពុលកាលណាប្រើ Desferal® ចំពោះអ្នកជំងឺដែលមានកំរិតជាតិដែកទាប ឬ កំរិត serum ferritin គ្រាន់តែកើនឡើងបន្តិចបន្តួច ។

## កំរិតប្រើ និង វិធីប្រើ

- កំរិតប្រើជាមធ្យម 20 – 60 mg/kg/day ចាក់បញ្ចូលក្រោមស្បែក (subcutaneous continuous infusion) ក្នុងរយៈពេល ៨ - ១០ ម៉ោងរៀងរាល់ថ្ងៃរយៈពេល ៥ (យ៉ាងតិច) ទៅ ៧ យប់ក្នុងមួយសប្តាហ៍ ។ ចំពោះកុមារ កំរិតប្រើចាប់ផ្តើមគឺ 20mg/kg/day (កំរិតប្រើខ្ពស់ជាងនេះមុនពេលលើសបន្ទុកជាតិដែកអាចប៉ះពាល់ដល់ការលូតលាស់ឆ្អឹង និង ការរីកធំធាត់) ។ ត្រូវបង្កើនកំរិតប្រើតាមការកើនឡើងបន្ទុកជាតិដែក ។ ជាទូទៅ កំរិតប្រើសមស្របជាមធ្យមប្រចាំថ្ងៃគឺ 50 mg/kg/day ។
- គោលបំណងរក្សាកំរិត serum ferritin អោយទាបជាង 1000 ng/ml ហើយមិនអោយលើសពី 2500 ng/ml ។
- Ascorbic acid (vitamin C) ជួយបង្កើនការបញ្ចេញជាតិដែកពេលប្រើរួមជាមួយ Desferal ។ ត្រូវចាប់ប្រើបន្ទាប់ពីព្យាបាលដោយ Deferrioxamine បានមួយខែ ។ ប្រើលេបតាមមាត់ក្នុងកំរិត 3 mg/kg/day ហើយត្រូវលេបភ្លាមពេលចាប់ផ្តើមចាក់ Deferrioxamine ។ Ascorbate ជួយកំចាត់ជាតិដែក តែវានឹងបង្កើនការខូចខាតបេះដូងទៅវិញ កាលណាប្រើវាតែឯង ដោយគ្មានឱសថកំចាត់ជាតិដែក (iron chelator) ។

## ផលវិបាកនៃ Desferal :

- ប្រតិកម្មលើស្បែកត្រង់កន្លែងចាក់
- Yersinia infection – បង្ហាញរោគសញ្ញាក្តៅខ្លួន ឈឺពោះ និង រាគ ។ ករណីនេះ ត្រូវបញ្ឈប់ Desferal ហើយព្យាបាលដោយ Cotrimoxazole ។
- ប្រតិកម្មធ្ងន់ធ្ងរ (កំរមាន)
- Desferal toxicity (ពេលប្រើកំរិតខ្ពស់ > 50 mg/kg/day) :
  - ពុលភ្នែក (ocular toxicity) – ថយចុះគំហើញ, ដែនគំហើញ និង ខ្វាក់មាន់ (night blindness) ; ធូរស្រាលវិលមកធម្មតាវិញពេលបញ្ឈប់ Desferal ។
  - ពុលត្រចៀក (auditory toxicity) – ធ្ងន់ត្រចៀក ។ ជួនកាលមិនវិលត្រឡប់មកធម្មតាវិញឡើយ ។
  - ការលូតលាស់យឺតយ៉ាវ (ការនេះកើតមានកាលណាការព្យាបាលចាប់ផ្តើមតាំងពីអាយុក្រោម ៣ ឆ្នាំ) ។

- ដំបៅឆ្អឹង (skeletal lesions) – អាការៈស្រដៀងនឹងជំងឺកង្វះ Vitamin D (pseudo rickets), បំរែបំរួលផ្នែកខាងចុងនៃឆ្អឹងវែង, ការលូតលាស់ឆ្អឹងកងខ្នងមានការយឺតយ៉ាវ ។ល ។ ( កើតមានកាលណាកំរិតប្រើខ្ពស់ ពេលបន្ទុកជាតិដែកស្ថិតនៅកំរិតទាប ) ។

**ថ្នាំកំចាត់ជាតិដែកលេបតាមមាត់ / *Oral iron chelators***

Deferasirox (Exjade®) ត្រូវបានគេប្រើដើម្បីព្យាបាលការលើសជាតិដែករ៉ាំរ៉ៃចំពោះអ្នកជំងឺអាយុចាប់ពី ២ ឆ្នាំឡើងទៅដែលបណ្តាលមកពីការបញ្ចូលឈាម (ប្រហែល 100 ml/kg/year ហើយ serum ferritin > 1000 ng/ml) ។

- មុនចាប់ផ្តើមប្រើ, ត្រូវដឹងពីកំរិត serum ferritin និង ជាតិដែកជាមុនសិន ។ អាចប្រឈមនឹងការពុលកាលណាប្រើ Exjade ចំពោះអ្នកជំងឺដែលមានកំរិតជាតិដែកទាប ឬ កំរិត serum ferritin គ្រាន់តែកើនឡើងបន្តិចបន្តួច ។
- កំរិតប្រើ : 20-30 mg/kg/day (ថ្មីៗនេះ FDA និង EMA [European Medicines Agency] បានឯកភាពអោយប្រើដល់កំរិត 40mg/kg/day) ។ ចាប់ផ្តើមប្រើកំរិត 20 mg/kg/day ចំពោះអ្នកជំងឺដែលបញ្ចូលឈាម បាន ១០ - ២០ ដង ។ កំរិតប្រើអាចតំឡើងដល់ 30 mg/kg/day ហើយករណីខ្លះដល់ 40 mg/kg/day ។ បន្ទាប់ពីចាប់ផ្តើមប្រើ, ត្រូវតំឡើង 5 - 10 mg/kg រៀងរាល់ ៣ ទៅ ៦ ខែម្តងដោយផ្អែកតាមកំរិតជាតិដែកបំរុង ។ វាមានសារសំខាន់ណាស់ក្នុងការពិនិត្យ ferritin រាល់ពេលបញ្ចូលឈាមម្តងៗ ហើយត្រូវប្រើបំរែបំរួលមធ្យមរវាងរង្វាស់ ៣ ទៅ ៥ ដងដើម្បីវាយតំលៃពីប្រសិទ្ធិភាពរបស់វា ។
- ទំរង់សុវត្ថិភាពនៃថ្នាំ Deferasirox គឺប្រហាក់ប្រហែលគ្នាចំពោះកុមារ និង មនុស្សពេញវ័យ ។ ការសិក្សាលើកុមារអាយុតិចជាង ២ ឆ្នាំ ទំនងដូចជាសុវត្ថិភាព ប៉ុន្តែការសិក្សានៅមានកំរិតនៅឡើយ ។

Deferiprone (L1/Deferriprox) ជាថ្នាំកំចាត់ជាតិដែកលេបតាមមាត់មួយប្រភេទទៀត អាចប្រើកាលណាការកំចាត់ជាតិដែកគ្មានប្រសិទ្ធិភាព ឬ មិនបានល្អ ទោះបីប្រើ Desferal® ឬ Exjade® ដល់កំរិតខ្ពស់ក៏ដោយ ឬ ថ្នាំកំចាត់ជាតិដែកផ្សេងទៀតត្រូវហាមមិនអោយប្រើ (contra-indicated) ។ វាមានគ្រោះប្រឈមនឹង agranulocytosis, arthritis & gastrointestinal disturbance បន្តិចបន្តួច តែអាចវិលមកធម្មតាវិញបានពេលបញ្ឈប់វា ។

- កំរិតប្រើប្រចាំថ្ងៃធម្មតា 75 mg/kg បីដងក្នុងមួយថ្ងៃ ហើយអាចតំឡើងដល់ 100 mg/kg បីដងក្នុងមួយថ្ងៃ ។
- កង្វះជាតិ Zinc អាចកើតមានជាពិសេសជាមួយ Deferiprone ហើយត្រូវការអោយវាបន្ថែម ។

### ការព្យាបាលដោយផ្គុំថ្នាំកំចាត់ជាតិដែក : ***Deferrioxamine* និង *Deferasirox***

ការព្យាបាលដោយផ្គុំ Deferrioxamine និង Deferasirox ស្ថិតនៅក្នុងការសិក្សានៅឡើយនាពេលបច្ចុប្បន្ននេះ ។ គេនៅពុំទាន់បានដឹងច្បាស់អំពីប្រសិទ្ធិភាព និង សុវត្ថិភាពនៃការព្យាបាលផ្គុំបញ្ចូលគ្នានៅឡើយទេ ។

### ការព្យាបាលដោយផ្គុំថ្នាំកំចាត់ជាតិដែក : ***Deferrioxamine* និង *Deferiprone***

ការព្យាបាលដោយផ្គុំ Deferrioxamine និង Deferiprone កំពុងតែត្រូវបានគេប្រើកាន់តែច្រើន ។ របៀបប្រើរួមមាន **ការប្រើឆ្លាស់គ្នា** និង **ការប្រើរួមគ្នា** នៃថ្នាំទាំងពីរ ។ តាមការសិក្សាបង្ហាញថា **ការប្រើឆ្លាស់គ្នា** (ឧទាហរណ៍ : បីថ្ងៃជាមួយ Deferrioxamine និង បួនថ្ងៃជាមួយ Deferiprone) ហាក់ដូចជាផ្តល់ភាពងាយស្រួលប្រើជាង ហើយរក្សាលំនឹងកំរិតជាតិដែកបានល្អ ។ ជាញឹកញយ Agranulocytosis អាចកើតមានក្នុងការព្យាបាលដោយផ្គុំនេះ ដូច្នេះត្រូវតាមដាន Neutrophils រៀងរាល់សប្តាហ៍ ។

តារាង ១ : ទំរង់ផ្សេងៗនៃថ្នាំកំចាត់ជាតិដែក

| Agent | Route | Half-life of drug (hours) | Schedule | Clearance | Side effects and toxicity |
|---|---|---|---|---|---|
| Deferrioxamine (Desferal) | Slow infusion : intraveinous or subcutaneous | 0.5 | 8 to 10 hours per day, 5 to 7 day per | Renal, hepatic | Dermatological, ocular, auditory |
| Deferasirox (Exjade) | Oral | 12 to 16 | Once daily | Hepatobiliary | Gastroinetsinal, renal, hepatic |
| Deferiprone (L1) | Oral | 2 to 3 | Three times per day | Renal, cardiac | Hematological (neutropenia, agranulocytosis), arthropathic |

តារាង ២ : ការតាមដានលក្ខណ:ពុលនៃថ្នាំកំចាត់ជាតិដែក

| | Deferrioxamine | Deferasirox | Deferiprone |
|---|---|---|---|
| Complete Blood Count (CBC); Absolute Neutrophil Count | | | រាល់សប្តាហ៍ |
| Liver function tests (LFT) | | រាល់ ៣ ទៅ ៤ អាទិត្យ | រៀងរាល់ ៣ ខែ |
| Creatinine | រៀងរាល់ ៣ ខែ | រាល់ ៣ ទៅ ៤ អាទិត្យ | រៀងរាល់ ៣ ខែ |
| Urine protein / Creatinine | រៀងរាល់ ៣ ខែ | រាល់ ៣ ទៅ ៤ អាទិត្យ | |
| Urine microalbulmin / Creatinine | រៀងរាល់ ៣ ខែ | រាល់ ៣ ទៅ ៤ អាទិត្យ | |
| Urine glucose | | រាល់ ៣ ទៅ ៤ អាទិត្យ | |
| Zinc, copper, calcium, and magnesium | រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ |
| Electrolytes | | រាល់ ៣ ទៅ ៤ អាទិត្យ | |
| Eye exam | រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ |
| Audiogram | រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ | រៀងរាល់ឆ្នាំ |
| Sitting height | រៀងរាល់ ២ ឆ្នាំ | រៀងរាល់ ២ ឆ្នាំ | រៀងរាល់ ២ ឆ្នាំ |
| Height / Weight | រៀងរាល់ ៦ ខែ | រៀងរាល់ ៦ ខែ | រៀងរាល់ ៦ ខែ |
| Clinical symptoms (nausea, diarrhea, color-vision change) | រាល់ ៣ ទៅ ៤ អាទិត្យ | រាល់ ៣ ទៅ ៤ អាទិត្យ | រាល់ ៣ ទៅ ៤ អាទិត្យ |

## 3. ការតាមដានពិនិត្យអ្នកជំងឺ / Monitoring of Patients

ក្នុងរយៈពេលអោយសំរាកពេទ្យដើម្បីបញ្ចូលឈាមម្តងៗ, ត្រូវធ្វើ និង កត់ត្រានូវចំណុចខាងក្រោមនេះ :

- វាយតំលៃគ្លីនិក (clinical assessment) - កំពស់, ទំងន់, ទំហំថ្លើម និង អណ្តើក ។

- កំរិត Hb មុនបញ្ចូលឈាម, ចំនួន Platelet និង កំរិត Hb ក្រោយបញ្ចូលឈាម (កន្លះម៉ោងក្រោយបញ្ចូលឈាម) ។
- បរិមាណឈាមត្រូវបញ្ចូល
- តើមានប្រតិកម្មភ្លាមៗ ឬ ប្រតិកម្មពេលក្រោយទេ ? (ត្រូវតែស្រាវជ្រាវរក allo red cell antibody) ។
- ឱសថផ្សេងៗ

**រៀងរាល់ ៦ ខែ :**

- វាយតំលៃការធំធាត់ និង ការលូតលាស់
- កំរិត Serum Ferritin
- មុខងារថ្លើម (LFT)

**រៀងរាល់ឆ្នាំ ឬ ញឹកញាប់ជាងបើសិនចាំបាច់ :**

- វាយតំលៃការធំធាត់ និង ការលូតលាស់
- វាយតំលៃក្រពេញ Endocrine – កំរិតជាតិស្ករ (RBS), T4/TSH, $Ca^{++}$, $PO_4$ (បើកំរិត $Ca^{++}$ ទាប - ត្រូវពិនិត្យ PTH និង Vitamin D)
- ការលូតលាស់ប្រដាប់ភេទ (sexual development) ចាប់ពីអាយុ ១០ ឆ្នាំទៅ
  - តារាងវាយតំលៃការលូតលាស់រាងកាយ (Tanner stage)
  - FSH/LH
  - Oestradiol/testosterone
- វិភាគរក Infection – Hepatitis B & C, HIV, Syphilis (VDRL)
- គុណគូរមើលបរិមាណឈាមដែលបានបញ្ចូល
- វាយតំលៃតុល្យភាពកំរិតជាតិដែក
- វាយតំលៃឆ្អឹង - Osteoporosis និង បំរែបំរួលឆ្អឹង (ត្រូវមានគំរោងធ្វើ X-rays និង DEXA scan ដែលជាឧបករណ៏វាស់កំហាប់សារធាតុរ៉ែរបស់ឆ្អឹង - BMD : bone mineral density)

**ការវាយតំលៃបេះដូង ត្រូវធ្វើម្តងរាល់ឆ្នាំបន្ទាប់ពីអាយុ ១០ ឆ្នាំទៅ ហើយធ្វើអោយបានញឹកញាប់កាលណារកឃើញមានភាពមិនប្រក្រតី ។**

## 4. ការវះកាត់អណ្តើកចេញ / Splenectomy

តំរូវការនៃកាត់អណ្តើកចេញ ចំពោះតាឡាសសេមី បានថយចុះច្រើនក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ការនេះមួយផ្នែកដោយសារមានការថយចុះអត្រានៃការរីកធំអណ្តើក (hypersplenism) ចំពោះអ្នកជំងឺដែលបានទទួលការបញ្ចូលឈាមត្រឹមត្រូវ ។

លក្ខ័ណ្ឌត្រូវកាត់អណ្តើកចេញ

- តំរូវការឈាមលើសមួយដងកន្លះពីធម្មតា ឬ > 220-250 ml/kg/year ជាមួយកំហាប់ឈាមក្រហម (packed red cells / Hct 75%) ដើម្បីរក្សាបានកំរិត Hb មធ្យម ហើយកុមារអាយុលើសពី ៥ ឆ្នាំ ។
- អណ្តើករីកធំខ្លាំង (hypersplenism)
- លទ្ធភាពវិវត្តិកើតជា Alloantibody ត្រូវតែផាត់ចេញ ។

ចាំបាច់ត្រូវចាក់វ៉ាក់សាំង Pneumococcal, Meningococcal និង Hib vaccinations (បើមិនទាន់បានចាក់ពីមុនមកទេ) អោយបាន ៤ - ៦ អាទិត្យមុនធ្វើការវះកាត់អណ្តើក ។

បន្ទាប់ពីវះកាត់អណ្តើករួច, អ្នកជំងឺគួរលេបថ្នាំ Penicillin-V ការពារ (250 mg ពីរដងក្នុងមួយថ្ងៃ) ហើយត្រូវណែនាំអោយប្រយ័ត្នដោយត្រូវមកពេទ្យជាបន្ទាន់ករណីមានក្តៅខ្លួនលើសពី ៣៨,៥$^{o}$C ។

ការវិវត្តិអោយកើនប្លាកែត (thrombocytosis) ក្រោយការវះកាត់អណ្តើកចេញក៏មានច្រើនដែរ ហេតុនេះតំរូវអោយលេប Aspirin កំរិតទាប (81 mg ក្នុងមួយថ្ងៃ) ប្រសិនបើ Thrombocytosis > 800,000/mm$^3$ ។ ផលវិបាកមួយទៀត វិវត្តិឡើងបន្ទាប់ពីកាត់អណ្តើកចេញ នោះជានិន្នាការងាយអោយកើតជំងឺ Thrombosis ។ ភាគច្រើនជា Venous thromboembolism ឧស្សាហ៍កើតមានចំពោះ Thalassemia intermedia និង Hb H-Constant Spring បន្ទាប់ពីកាត់អណ្តើកចេញ ។

## 5. របបអាហារ និង សារធាតុបន្ថែម / Diet and Supplement

- Folic acid កំរិតទាប 1 mg លេបប្រចាំថ្ងៃអាចមានអត្ថប្រយោជន៍ចំពោះអ្នកជំងឺភាគច្រើន ។
- Vitamin C កំរិតទាប 3 mg/kg បង្កើនការបញ្ចេញជាតិដែកចំពោះអ្នកជំងឺប្រើ Desferral ។ កំរិតប្រើ : 50 mg រាល់ថ្ងៃចំពោះអ្នកជំងឺអាយុតិចជាង ១០ ឆ្នាំ, ហើយ 100 mg រាល់ថ្ងៃចំពោះអ្នកជំងឺអាយុលើសពី ១០ ឆ្នាំ ។ គេប្រើតែចំពោះអ្នកជំងឺដែលព្យាបាលជាមួយ Desferal ប៉ុណ្ណោះ ។
- ត្រូវចៀសវាងអាហារណាដែលសំបូរជាតិដែក ដូចជាសាច់ពណ៌ក្រហម និង គ្រាប់ធញ្ញជាតិដែលគេបន្ថែមជាតិដែក ។
- ទឹកតែអាចជួយកាត់បន្ថយការបឺតស្រូបជាតិដែកតាមបំពង់រំលាយអាហារ ។
- គេលើកទឹកចិត្តអោយទទួលទានអាហារដែលផលិតពីទឹកដោះគោ ព្រោះវាសំបូរដោយកាល់ស្យូម ។

## 6. ការចាក់ថ្នាំបង្ការ / Vaccinations

ការចាក់វ៉ាក់សាំងអោយបានសមស្រប ជាការចាំបាច់ណាស់ចំពោះអ្នកជំងឺតាឡាសេមីទាំងអស់ ជាពិសេសអ្នកជំងឺដែលទទួលការបញ្ចូលឈាម និង អ្នកជំងឺដែលត្រូវបានកាត់អណ្តើកចេញ ។ កម្មវិធីចាក់ថ្នាំបង្ការចំពោះកុមារត្រូវតែធ្វើបច្ចុប្បន្នភាព ហើយកត់ត្រាអោយបានត្រឹមត្រូវរៀងរាល់ឆ្នាំ ។ វ៉ាក់សាំង hepatitis B ត្រូវចាក់អោយគ្រប់ដូស យ៉ាងហោចណាស់ក៏មុនចាប់ផ្តើមបញ្ចូលឈាមលើកដំបូងដែរ ។

មុនធ្វើការវះកាត់អណ្តើក, អ្នកជំងឺត្រូវទទួលវ៉ាក់សាំងបង្ការ (បើមិនទាន់បានចាក់ពីមុនមកទេ) ប្រភេទ meningococcal vaccine (Meningo A+C®) និង pneumococcal vaccine (23-valent

Pneumo-23®), ហើយត្រូវធ្វើបច្ចុប្បន្នភាពវ៉ាក់សាំង Hib ។ គួរពិចារណាចាក់រំលឹក 23-valent pneumococcal vaccine (Pneumo-23®) រៀងរាល់ ៥ - ១០ ឆ្នាំម្តង ។

អ្នកជំងឺត្រូវការចាក់វ៉ាក់សាំងបង្ការចំពោះ hepatitis A និង hepatitis B ជាពិសេសអ្នកជំងឺដែលទទួលការបញ្ចូលឈាមជាប្រចាំ ។ ចំពោះអ្នកជំងឺដែលផ្ទុកមេរោគ HIV ឬ កំពុងព្យាបាល hepatitis C មិនគួរទទួល live virus vaccines ឡើយ ។ ឯវ៉ាក់សាំងផ្តាសាយ ក៏គួរចាក់ជាប្រចាំឆ្នាំដែរ ។

## 7. ការបង្ករោគរាតត្បាតស្រួចស្រាវ / Acute Infection

Acute infection ស្ថិតនៅជាមូលហេតុចំបងបណ្តាលអោយស្លាប់ចំពោះអ្នកជំងឺតាឡាសសេមី ។ ជំហានប្រកបដោយប្រុងប្រយ័ត្នក្នុងការសំគាល់ និង ព្យាបាល Infections ធ្ងន់ធ្ងរ នឹងការពារអត្រាស្លាប់ដែលមិនសមស្របបាន ។ អ្នកជំងឺត្រូវទទួលការអប់រំអំពីការថែទាំពេលក្តៅខ្លួន និង រោគសញ្ញាស្រួចស្រាវ ។ ភាពងាយស្រួលរកកំណត់ត្រាវេជ្ជសាស្ត្រ (Medical Records) អាចជួយដល់ការវាយតំលៃ និង ការព្យាបាលបានឆាប់រហ័សដល់អ្នកជំងឺ ។ ការនេះអាចសំរួលបានដោយអ្នកជំងឺកាន់ប័ណ្ណសុខភាព (Health Records) ដែលកត់ត្រាអំពីរោគវិនិច្ឆ័យ ផលវិបាក និង ការព្យាបាល ។

ការប្រើ Prophylactic antibiotics ចំពោះអ្នកជំងឺកាត់អណ្តើក អាចកាត់បន្ថយគ្រោះប្រឈមនឹង pneumococcal infections បាន ។ យ៉ាងណាក៏ដោយ ពួក gram-negative organisms ជាមូលហេតុចំបង នៃការបង្ករោគដោយពួកបាក់តេរី ចំពោះអ្នកជំងឺតាឡាសសេមី ។ ការព្យាបាលជាបន្ទាន់ ជាមួយ broad spectrum antibiotics គួរធ្វើភ្លាម មុនពេលបានលទ្ធផលនៃការបណ្តុះឈាម (blood cultures) ។ អ្នកជំងឺតាឡាសសេមីដែលប្រើ Desferal មានគ្រោះខ្ពស់ប្រឈមនឹង Yersinia enterocolitica ដែលជាប្រភេទបាក់តេរីចូលចិត្តជាតិដែក ។ វាអាចបង្ហាញរោគសញ្ញាគ្លីនិកក្តៅខ្លួន, ឈឺពោះ និង រាគ ។ Antibiotics គួរចាប់ផ្តើមភ្លាមមុនបានលទ្ធផលនៃការបណ្តុះលាមក និង ឈាម ។ ជាទូទៅ គួរបញ្ឈប់គ្រប់ការព្យាបាលកំចាត់ជាតិដែក រហូតដល់អាការៈក្តៅខ្លួនត្រូវបានព្យាបាលបានត្រឹមត្រូវ ។

## ឯកសារពិគ្រោះ / **References**


[1] Lieyman JS, Hann IM. Paediatric Haematology. London, Churchill Livingston, 1992.

[2] Current Pediatric Therapy, 18th ed., 2006 Sauders

[3] Standards for the Clinical Care of Children and Adults with Thalassaemia in the UK. 2nd edition 2008

[4] Standards of Care Guidelines for Thalassemia, published in 2008 by Children's Hospital & Research Center Oakland Hematology/Oncology Department. www.childrenshospitaloakland.org

[5] Prevention of thalassemia and other hemoglobin disorders, Volume 1, 2nd edition published by TIF 2005. www.thalassaemia.org.cy

[6] Guidelines Thalassaemia, 2nd revised edition of Clinical Management (N°9), published by TIF 2008. www.thalassaemia.org.cy

KINGDOM OF CAMBODIA

NATION RELIGION KING

Ministry of Health

# Guidelines for the Clinical Management of Patients with Thalassaemia in Cambodia



For Hospital Practice

Preventive Medicine Department

Non Communicable Disease Prevention & Control

Phnom Penh, September 2011

